# របាយការណ៍ប្រជុំប្រចាំខែមករា ឆ្នាំ២០២០
# ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី**

នាព្រឹកថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំរួមប្រចាំខែមករា ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាមន្ត្រីទាំងអស់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាកិច្ចចាប់ផ្តើមឯកឧត្តមទេសរដ្ឋមន្ត្រីបានមានប្រសាសន៍ស្វាគមន៍ និងបានថ្លែងកោតសរសើរមន្ត្រីរាជការទាំងអស់ដែលបានធ្វើការយ៉ាងសកម្ម និងបានទទួលលទ្ធផល។ ជាមួយគ្នានោះ ឯកឧត្តមបានណែនាំថា ត្រូវបន្តប្រឹងប្រែងទាំងអស់គ្នា ដើម្បីការរីកចំរើនរបស់ស្ថាប័ន និងទទួលបានជំនឿទុកចិត្តពីថ្នាក់ដឹកនាំ។ បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រីបានអនុញ្ញាតជូនឯកឧត្តម ឈឹម ឃិនដារ៉េត អគ្គលេខាធិការ ធ្វើបទបង្ហាញស្តីអំពីរបាយការណ៍វឌ្ឍនភាពនៃលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលជាសមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយបង្ហាញពីភាពប្រសើរ និងភាពប្រឈម ប្រចាំខែមករា ឆ្នាំ២០២០ និងលើកទិសដៅសម្រាប់ខែបន្ទាប់។

បន្ទាប់ពីស្តាប់របាយការណ៍ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានដាក់នូវវិធានការណ៍ និងធ្វើការណែនាំ ដល់ថ្នាក់ដឹកនាំ និង មន្ត្រីទាំងអស់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពីរបៀបរបបក្នុងការអនុវត្តការងារជាពិសេសការពង្រឹងសាមគ្គីភាព និងឯកភាពផ្ទៃក្នុង។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបន្តថា ថ្នាក់ដឹកនាំទាំងអស់ ត្រូវធ្វើជាគំរូគេ មានភាពស្វិតស្វាញក្នុងការងារ និងមានវិន័យឱ្យខ្ពស់ជាងគេដែរ។ ជាមួយគ្នានោះ វត្តមានក្នុងការបំពេញការងារតាមច្បាប់កំណត់ និងបំពេញការងារតាមបំណែងចែកតួនាទី និងភារកិច្ចរៀងៗខ្លួនឱ្យបានល្អ។

- ក្រុមតេឡេក្រាមថ្នាក់ដឹកនាំអ.ជ.ប.ជ.អ ត្រូវដាក់បញ្ចូល អនុប្រធាន ទីប្រឹក្សា ជំនួយការ អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋាន ដើម្បីងាយស្រួលក្នុងការទំនាក់ទំនង ចែករំលែកព័ត៌មាន និងអញ្ជើញចូលរួមក្នុងកម្មវិធីផ្សេងៗ។ ចំពោះការអញ្ជើញ ឬសេចក្តីជូនដំណឹងតាមតេឡេក្រាមនេះ ត្រូវចាត់ទុកជាឯកសារផ្លូវការ។
- ចំពោះលិខិតស្នើសុំអនុញ្ញាតច្បាប់ ត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ពីការិយាល័យបុគ្គលិកនៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អំពីថ្ងៃដែលបានស្នើសុំឈប់សម្រាករួចហើយ និងថ្ងៃដែលនៅសល់ភ្ជាប់មកជាមួយ។ ក្នុងករណីពុំមានការបញ្ជាក់ច្បាស់លាស់ក្នុងកំណត់បង្ហាញពីការិយាល័យបុគ្គលិកនៃនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទេ នឹងមិនអនុញ្ញាតច្បាប់ជូនឡើយ។
- អគ្គលេខាធិការដ្ឋាន ត្រូវផ្តល់របាយការណ៍សកម្មភាព នៅរៀងរាល់ថ្ងៃសុក្រឱ្យបានទៀងទាត់។ ក្នុងនោះ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ពី ស្ថានភាពបុគ្គលិក លិខិតចេញ ចូល បេសកកម្ម

បញ្ជីវត្តមាន បេឡាសាច់ប្រាក់ សមតុល្យចំណូលចំណាយ ថវិកាជាតិ និងថវិកាជំនួយ។ ចំពោះរបាយការណ៍ប្រចាំខែ អនុប្រធានអ.ជ.ប.ជ.អ និងអគ្គលេខាធិការដ្ឋាន ត្រូវដាក់ជូនខុទ្ទកាល័យនៅថ្ងៃទី២២ នៃខែនីមួយៗ។ ចំពោះមន្ត្រីជាប់កិច្ចសន្យា ដែលខ្វះសមត្ថភាពត្រូវបណ្តុះបណ្តាលបំពេញសមត្ថភាពទាំងភាសាអង់គ្លេស និងជំនាញបច្ចេកទេសពាក់ព័ន្ធនិងការងារអេដស៍។ អគ្គលេខាធិការដ្ឋាន ត្រូវរៀបចំបើកវគ្គបណ្តុះបណ្តាល ហើយធ្វើការតាមដាន និងវាយតម្លៃសារជាថ្មី ចំពោះអ្នកដែលអាចបន្ត ឬបញ្ចប់កិច្ចសន្យានៅពាក់កណ្តាលឆ្នាំ២០២០។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រីបានអនុញ្ញាតឱ្យឯកឧត្តម លោកជំទាវជាអនុប្រធានមានមតិយោបល់ ក្នុងនោះ ៖

១- លោកជំទាវ ស៊ឹម ខេងខាំ បានស្នើសុំដាក់បញ្ចូលរបាយការណ៍ការងារបក្ស ការងារឃោសនាអប់រំនយោបាយ ការផ្សព្វផ្សាយជំនួយស្មារតី និងស្នើសុំការបណ្តុះបណ្តាលអំពីជំងឺអេដស៍ដោយផ្សារភ្ជាប់ជាមួយយ៉ែនឌ័រ។

២- ឯកឧត្តម គង់ រដ្ឋា បានណែនាំថា ចំពោះរបាយការណ៍ អគ្គលេខាធិការដ្ឋានត្រូវធ្វើជូនខុទ្ទកាល័យឱ្យបានទៀងទាត់។ ខុទ្ទកាល័យគ្រាន់តែមានតួនាទីប្រមូល និងស្រង់ឯកសារ រួចផ្ញើជូនអនុប្រធានប្រចាំការដើម្បីបូកសរុប។ ជាមួយគ្នានោះ នាយកដ្ឋានទាំងអស់ត្រូវត្រួតពិនិត្យរបាយការណ៍របស់ការិយាល័យនីមួយៗដោយយកចិត្តទុកដាក់មុនផ្ញើជូនអគ្គលេខាធិការពិនិត្យ។ គ្រប់របាយការណ៍ទាំងអស់ត្រូវវាយកុំព្យូទ័រ និងហាមមិនឱ្យសរសេររបាយការណ៍ឱ្យគ្នាឡើយ។

៣- ឯកឧត្តម ជា ប៉ោ បានស្នើថា មិនគួរយកខ្លឹមសារដែលបានផ្សាយក្នុងគណនី Facebook ផ្លូវការរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទៅផ្សព្វផ្សាយក្នុង Facebook ផ្ទាល់ខ្លួនទេ។ ការធ្វើបែបនេះ បណ្តាលឱ្យអ្នកអានឃើញថាផ្សាយខ្លឹមសារសកម្មភាពដដែលៗជាន់គ្នា។ ជាមួយគ្នានោះ សូមឱ្យអ្នកអានជួយ like និង share ផង។

៤- ឯកឧត្តម ស៊ឹម គឹមសែន បានស្នើឱ្យឯកឧត្តមអគ្គលេខាធិការរៀបចំធ្វើបច្ចុប្បន្នភាពសមាសភាពគណៈកម្មាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ឯចំពោះការអានអត្ថបទក្នុង Facebook ឯកឧត្តមលើកឡើងថា ជាសិទ្ធរបស់អ្នកអានដែលគេចង់ like ឬshare។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រីបានណែនាំឱ្យឯកឧត្តមអគ្គលេខាធិការរៀបចំវគ្គបណ្តុះបណ្តាល ជាពាកម្រិត គឺចាប់ពី អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន ដល់មន្ត្រីដែលបានតាំងស៊ប់ ដើម្បីបំពេញបន្ថែមសមត្ថភាព។ ចំពោះរបាយការណ៍ទាំងអស់ ត្រូវផ្ញើជូនខុទ្ទកាល័យ ជាឯកសារផ្លូវការ Hard Copy និងក្រុមតេឡេក្រាម ជាឯកសារSoft Copy។ ដោយឡែករបាយការណ៍អំពីការងារបក្ស ឯកឧត្តមទេសរដ្ឋមន្ត្រី បានណែនាំថា ឱ្យធ្វើរបាយការណ៍អំពីការងារបក្ស កុំឱ្យច្របូកច្របល់ជាមួយការងាររបស់រាជរដ្ឋាភិបាល។ ឯអ្នកដែលទទួលខុសត្រូវប្រព័ន្ធព័ត៌មានវិទ្យា (IT) ត្រូវខិតខំចុះផ្សាយព័ត៌មានឱ្យបានលឿនដោយទៅទទួលឯកសារពីខុទ្ទកាល័យ។

ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០

3-2-20

**នាយកខុទ្ទកាល័យ**



